## Asking “What is he/she doing?”



១ ធារី៖ ពិសិដ្ឋ មើលនូក! គាត់កំពុងធ្វើអីហ្នឹង?
ពិសិដ្ឋ៖ នៅណា?
ធារី៖ នោះ! បងប្រុសមួយពាក់អាវពណ៌ទឹកក្រូចនៅមុខហ្នឹង។
ពិសិដ្ឋ៖ អឺម... ខ្ញុំអត់ដឹងដែរ។ មើលទៅដូចកំពុងជួសជុលអី។
២ ធារី៖ ពិសិដ្ឋ មើលនោះមើល! បងតារាកំពុងធ្វើអីហ្នឹង?
ពិសិដ្ឋ៖ នៅណា? អត់ឃើញ។
ធារី៖ ងាកមើលខាងស្តាំដៃពិសិដ្ឋឯងមើល។
ពិសិដ្ឋ៖ អូ! គាត់កំពុងរៀបចំម៉ាស៊ីនបញ្ចាំងស្លាយសម្រាប់ប្រជុំល្ងាចហ្នឹងហ្នឹងណា។
៣ ធារី៖ បងតារា! បងកំពុងធ្វើអីហ្នឹង?
តារា៖ អូ ធារី! បងកំពុងរៀបចំម៉ាស៊ីនបញ្ចាំងស្លាយហ្នឹងណា។
ធារី៖ រៀបចំធ្វើអីបង? មានប្រជុំអីមែន?
តារា៖ ហ្នឹងហើយ មានប្រជុំល្ងាចហ្នឹង។

| | |
|---|---|
| នូក = នោះ | that |
| មើលនូក = មើលនោះ | Look at that! |
| បងប្រុស | brother |
| នៅមុខហ្នឹង | in front of [us] |
| អឺម... | hmm... |
| មើលទៅដូច | it looks as if |
| ជួសជុល | to repair, to fix |
| អត់ឃើញ | I don’t see it / I can’t see it |
| ងាកមើលខាងស្តាំដៃ | look on the right / turn to the right (to look) |
| ម៉ាស៊ីនបញ្ចាំងស្លាយ | slide projector |
| ប្រជុំ | meeting |
| ... ហ្នឹងណា | It’s just (that) ... |
| រៀបចំធ្វើអី | What are [you] preparing it for? / Why are [you] preparing it? |

Copyright © 2017 www.aakanee.com – This document is provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

| | |
|---|---|
| ហ្នឹងហើយ | yes, you're right |

## Cultural notes

ការសួរថា កំពុងធ្វើអីហ្នឹង [ឈ្មោះ/បង/អូន/ម៉ាក់ ជាដើម]? គឺជាការផ្តើមការសន្ទនាជាទូទៅ និងបង្ហាញភាពស្និទ្ធស្នាលមួយ។ ប៉ុន្តែ ពេលខ្លះ អ្នកអាចនឹងទទួលបានចម្លើយថា មានអី។ នេះមានន័យថា អ្នកឆ្លើយខ្ជិលឬមិនចង់ពន្យល់ប្រាប់យើងនោះទេ។ ប៉ុន្តែ ចម្លើយបែបនេះមិនចាត់ទុកថាជាការមិនគួរសមអ្វីឡើយ។

| | |
|---|---|
| ការសន្ទនា | conversation |
| ភាពស្និទ្ធស្នាល | closeness |
| មានអី | [it's] nothing |
| ខ្ជិល | lazy |
| ពន្យល់ប្រាប់ | to explain |
| [ត្រូវបាន]ចាត់ទុកថាជា | [has to be] considered as |
| ការមិនគួរសម | impoliteness |

## Additional dialogue

ធារី៖ តស់ទៅមើលបងតារាគាត់កំពុងធ្វើអីគេ។
ពិសិដ្ឋ៖ កុំរំខានគាត់អី។ មើលទៅគាត់ដូចរវល់ណាស់។
ធារី៖ មានទៅអី! តស់ ទៅសួរគាត់លេង។ មិនទើសទែងអីទេ។

| | |
|---|---|
| តស់... | Let's ... |
| រំខាន | to bother, to annoy, to disturb |
| កុំ ... អី | [we/you] should not ... |
| មើលទៅគាត់ដូច... | it looks as if he's ... / he looks ... |
| រវល់ | busy |
| មានទៅអី! | I think it's alright! |
| ទើសទែង | to get in the way of, to obstruct |

Copyright © 2017 www.aakanee.com – This document is provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.